# ឯកសារបណ្តុះបណ្តាល និងការអភិវឌ្ឍន៍សមត្ថភាព សារសោរគម្រោងរបស់សហគមន៍នេសាទ

អង្គការអភិរក្សអន្តរជាតិ – កម្ពុជា

ធ្នូ ២០២៣

# មាតិកា

១. គម្រោងស្នើសុំ ........ 2

១.១ តើគម្រោងគឺជាអ្វី? ........ 2

១.២ វដ្តរបស់គម្រោង ........ 2

២ សមាសភាពសំខាន់ៗនៅក្នុងការបង្កើតគម្រោង ........ 4

៣ អ្នកពាក់ព័ន្ធក្នុងគម្រោង ........ 5

៤ ប្រភេទមូលនិធិ ........ 6

៥ ដំណើរការនៃការដាក់សំណើគម្រោង ........ 7

៥ ទម្រង់នៃសំណើគម្រោង ........ 8

៦. លិខិតរដ្ឋបាល របាយការណ៍ និងកំណត់ហេតុ ........ 10

ឧបសម្ព័ន្ធ ១ គំរូទម្រង់គម្រោងស្នើសុំ ........ 11

ឧបសម្ពន្ធ័ទី២ គំរូទំរង់នៃគម្រោងផែនការសកម្មភាពរបស់គម្រោង ........ 20

ឧបសម្ព័ន្ធទី ៣ គំរូគម្រោងផែនការ និង តារាងត្រួតពិនិត្យតាមដាន វាយតម្លៃ ........ 26

ឧបសម្ព័ន្ធទី ៤ ទម្រង់កំណត់ហេតុ ........ 29

ឧបសម្ព័ន្ធទី ៥ គំរូកំណត់ហេតុ ........ 30

ឧបសម្ព័ន្ធទី ៦ ទម្រង់របាយការណ៍ ........ 34

# ១. គម្រោងស្នើសុំ

## ១.១ តើគម្រោងគឺជាអ្វី?

ការអោយនិយមន័យទៅលើពាក្យថា "គម្រោង" គឺមាននៅក្នុងឯកសារជាច្រើនដូចបានរៀបរាប់ខាងក្រោមនេះ៖

(១) គម្រោងគឺជាកញ្ចប់សកម្មភាពទាក់ទងគ្នាដែលប្រើថវិកា បុគ្គលិក និងធនធានផ្សេងៗទៀតដែលមានកំណត់ក្នុងរយៈពេលមួយជាក់លាក់ ដើម្បីសម្រេចបាននូវគោលបំណងមួយ រឺច្រើន។

(២) គម្រោងគឺជាបណ្តុំនៃកិច្ចការដែលត្រូវបង្កើតឡើង និងត្រូវបំពេញទៅតាមពេលវេលាកំណត់ជាក់លាក់ មានក្រុមការងារ អ្នកទទួលខុសត្រូវ និងមានប្រភពធនធានក្នុងការគាំទ្រអនុវត្ត ដើម្បីសម្រេចគោលដៅដែលឆ្លើយតបទៅនឹងតម្រូវការ រឺដើម្បីដោះស្រាយបញ្ហាដែលបានរកឃើញ។

(៣) គម្រោងគឺជាកិច្ចខិតខំប្រឹងប្រែងបណ្តោះអាសន្នដែលធ្វើឡើងដើម្បីបង្កើតជា ផលិតផល សេវាកម្ម ឬលទ្ធផល។ លំដាប់លំដោយនៃកិច្ចការដែលទាក់ទងគ្នាជាមួយនឹងកាលបរិច្ឆេទចាប់ផ្តើម និងបញ្ចប់ ព្រមទាំងធនធាន និងថវិកាជាក់លាក់។

គម្រោងសហគមន៍គម្រោងអាចមានទំហំធំ ឬតូច សាមញ្ញ ឬស្មុគស្មាញ ប៉ុន្តែពួកវាទាំងអស់មាន លក្ខណៈស្រដៀងគ្នាមួយចំនួនដូចជា វាមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពសង្គម សេដ្ឋកិច្ច បរិស្ថាន និងបង្កអោយមានភាពស្អិតរមួតក្នុងសង្គម របស់ក្រុមមនុស្សជាក់លាក់មួយ។ ឧទាហរណ៍ដូចជា គម្រោងស្តារព្រៃលិចទឹកឡើងវិញ គម្រោងសម្អាតបរិស្ថានសហគមន៍ គម្រោងស្តារតំបន់អភិរក្សត្រីមេពូជ គម្រោងកែច្នៃផលនេសាទ ។ល។ គម្រោងសហគមន៍ ដែលទទួលបានជោគជ័យទាមទារឱ្យមានការរៀបចំផែនការដោយប្រុងប្រយ័ត្ន កិច្ចសហការ និងការផ្តោតលើដំណោះស្រាយប្រកបដោយនិរន្តរភាព ដើម្បីសម្រេចបានគោលបំណងរបស់គម្រោង វាទាមទារអោយមានការបញ្ចូលគ្នានូវធនធានរបស់ស្ថាប័ន អង្គការ សហគមន៍នានា ក្នុងការអនុវត្តគម្រោង។

## ១.២ វដ្តរបស់គម្រោង

ជាទូទៅវដ្តរបស់គម្រោងមាន ៤ ដំណាក់កាលសំខាន់ៗដូចជា៖

(១) *ការផ្តួចផ្តើមគំនិត៖* ពិនិត្យលើភាពចាំបាច់និងពិនិត្យមើលលើលទ្ធភាពដែលគម្រោងអាចដំណើរ ការទៅបាន រឺ មិនបាន។ ប្រសិនបើគម្រោងអាចដំណើរការបាន គេនឹងបន្តទៅដំណាក់កាលបន្តទៀត។

(២) *គ្រោង និងដំណាក់កាលបង្កើតគម្រោង៖* គឺត្រូវរៀបចំផែនការគម្រោងដែលរួមបញ្ចូលកិច្ចការទាំងអស់ដែលត្រូវតែបំពេញក្នុងដំណាក់កាលផ្សេងៗគ្នា។ នៅក្នុងដំណាក់កាលនេះ ផែនការធនធាន ដែលរួមបញ្ចូលនូវបញ្ជីនៃធនធានមនុស្ស និងជំនាញដែលចាំបាច់សម្រាប់ កិច្ចការជាក់លាក់ និងផែនការគ្រប់គ្រងហានិភ័យ ដើម្បីធ្វើការប៉ាន់ប្រមាណនូវអ្វីដែលអាចកើតមានលើគម្រោងនេះ គឺត្រូវបញ្ចូលនៅក្នុងការបង្កើតគម្រោងនេះ ដើម្បីកាត់បន្ថយនូវហានិភ័យ និងផលប៉ះពាល់ផ្សេងៗ។ ការរៀបចំរចនាសម្ព័ន្ធឋានានុក្រមនៃការទំនាក់ទំនងដើម្បីកំណត់ថាអ្នកណាគួរតែទទួលបន្ទុកទំនាក់ទំនងក្នុងរយៈពេលដែលគម្រោងត្រូវបានបង្កើតឡើង ក៏មានសារៈសំខាន់ផងដែរ។

(៣) *ដំណាក់កាលអនុវត្តៈ* គឺជាដំណាក់កាលដែលមនុស្សគ្រប់គ្នាត្រូវមានតួនាទី និងទទួលខុសត្រូវ ហើយចាប់ផ្តើមធ្វើការលើគម្រោងខ្លួនឯង ជាមួយនឹងផែនការដែលបានរៀបចំរួចជាស្រេចក្នុងដំណាក់កាលគ្រោង និងបង្កើតគម្រោង។ អ្នកទទួលខុសត្រូវទាំងអស់ ត្រូវតែខិតខំប្រឹងប្រែងក្នុងការបំពេញភារកិច្ចដែលបានកំណត់ ចំណែកអ្នកគ្រប់គ្រងគម្រោងមានតួនាទីក្នុងការតាមដាន ត្រួតពិនិត្យ និងធ្វើឱ្យប្រាកដថាផែនការនឹងដំណើរការដូចការរំពឹងទុក។ នៅក្នុងដំណាក់កាលអនុវត្តគម្រោង ការបញ្ចូលអ្នកពាក់ព័ន្ធគ្រប់ភាគី និងការធ្វើបច្ចុប្បន្នភាពពីដំណើរការរបស់គម្រោងគឺមានសារៈសំខាន់ណាស់ ដើម្បីធានាឱ្យអ្នកពាក់ព័ន្ធទាំងអស់ មានអារម្មណ៍ថាពួកគេត្រូវបានរួមបញ្ចូល ១០០% នៅក្នុងដំណើរការទាំងនេះ។

(៤) *ដំណាក់កាលត្រួតពិនិត្យតាមដានៈ* បន្ទាប់ពីឆ្លងកាត់ដំណាក់កាលនៃការអនុវត្តគម្រោង គឺជាពេលវេលាដើម្បីត្រួតពិនិត្យ និងតាមដានដើម្បីប្រាកដថាអ្វីៗដំណើរការដូចការរំពឹងទុក។ សូចនាករសំខាន់ៗក្នុងការត្រួតពិនិត្យតាមដានរួមមានៈ

ថវិកាៈ តាមដានលើការចំណាយថវិការបស់អ្នក តើអ្នកបានចំណាយត្រឹមត្រូវ ដូចទៅនឹងផែនការរបស់អ្នក រឺទេ?

ពេលវេលាៈ វាមានសារៈសំខាន់ណាស់ក្នុងការតាមដានពេលវេលាក្នុងការអនុវត្តសកម្មភាពរបស់គម្រោង ដើម្បីធានាថាក្រុមការងាររបស់អ្នកអាចបញ្ចប់កិច្ចការនីមួយៗបានទាន់ពេលវេលា និងមានប្រសិទ្ធភាពតាមដែលអាចធ្វើទៅបាន។ បន្ថែមពីលើនេះទៀត អ្នកត្រូវប្រាកដថាពេលវេលាដែលបានកំណត់សម្រាប់កិច្ចការនីមួយៗគឺសមរម្យសម្រាប់គ្រប់គ្នា។

ហានិភ័យៈ ការតាមដានហានិភ័យនៃគម្រោងណាមួយ គឺដើម្បីត្រៀមខ្លួនសម្រាប់ទប់ទល់ និងដោះស្រាយ ដើម្បីកាត់បន្ថយហានិភ័យ និងផលប៉ះពាល់ផ្សេងៗដែលអាចកើតមានឡើងក្នុងការអនុវត្ត គម្រោង។

ការផ្លាស់ប្តូរៈ តាមដានពីសក្តានុពលនៃការផ្លាស់ប្តូរសំខាន់ៗដែលអាចកើតឡើងនៅក្នុងគម្រោងហើយអ្នកអាចព្យាករណ៍ពីភាពចាំបាច់នៃការផ្លាស់ប្តូរសកម្មភាពការងារផ្សេងៗ អោយបានទាន់ពេលវេលា ជំនួសឱ្យការដោះស្រាយវានៅនាទីចុងក្រោយ។

គុណភាពៈ តាមដានពីគុណភាពនៃលទ្ធផលការងាររបស់អ្នកក្នុងអំឡុងពេលអនុវត្តគម្រោងដើម្បីឱ្យប្រាកដថាកម្រិតនៃការពេញចិត្តគឺខ្ពស់គ្រប់ពេលវេលា។

*(៥) ដំណាក់កាលបញ្ចប់គម្រោងៈ* គឺជាដំណាក់កាលដ៏សំខាន់បំផុតមួយនៃវដ្តគម្រោង ព្រោះវាបានផ្សារភ្ជាប់អ្វីៗទាំងអស់ជាមួយគ្នាតាំងពីដំណាក់កាលចាប់ផ្តើម រហូតដល់ការបញ្ចប់គម្រោង។ នៅក្នុងការបិទបញ្ចប់គម្រោង អ្នកអាចវាយតម្លៃលើការអនុវត្តការងាររបស់ក្រុម នៅគ្រប់ដំណាក់កាល ហើយប្រមូលម៉ូនូវឯកសារសំខាន់ៗដែលបានព្រាងទុកនៅក្នុងដំណាក់កាលនេះ។




រូបភាព ១ វដ្តនៃគម្រោង

## ២ សមាសភាពសំខាន់ៗនៅក្នុងការបង្កើតគម្រោង

សមាសធាតុសំខាន់ៗមួយចំនួនដែលមានសារៈសំខាន់សម្រាប់ពិចារណា និងគួរតែបញ្ចូលទៅក្នុងសរសេរគម្រោងមានដូចជា៖

**ការវាយតម្លៃតម្រូវការ៖** អ្នកត្រូវវាយតម្លៃពីតម្រូវការជាក់ស្តែងឱ្យបានហ្មត់ចត់ វាគឺជាជំហានដំបូងក្នុងការយល់ដឹងអំពីបញ្ហាប្រឈម និងឱកាសនៅក្នុងសហគមន៍។ វាពាក់ព័ន្ធនឹងការប្រមូលទិន្នន័យ ការចូលរួមជាមួយសមាជិកសហគមន៍ និងការកំណត់អត្តសញ្ញាណអាទិភាព ចំណុចខ្លាំង និងផ្នែកសម្រាប់ការកែលម្អរដើម្បីដោះស្រាយ ឬ ធ្វើអោយប្រសើរឡើងវិញ។

**កំណត់គោលបំណងច្បាស់លាស់៖** គម្រោងដែលបង្កើតឡើងត្រូវតែមានគោលបំណងច្បាស់លាស់ ជាក់លាក់ ហើយអាចវាស់វែងបាន។ ការកំណត់គោលបំណងរបស់គម្រោងអោយបានច្បាស់លាស់គឺមានសារៈសំខាន់ណាស់ វាអាចជួយអោយការអនុវត្ត និងគ្រប់គ្រងគម្រោងមានភាពរលូន ហើយឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង ហើយបញ្ហាដែលកើតមាននៅក្នុងសហគមន៍ត្រូវបានដោះស្រាយ។

**ការចូលរួមសហគមន៍៖** ការចូលរួមយ៉ាងសកម្ម និងការចូលរួមរបស់សមាជិកសហគមន៍ទូទាំងគម្រោងគឺចាំបាច់ណាស់។ ចូលរួមពួកគេនៅក្នុងដំណើរការធ្វើការសម្រេចចិត្ត ស្នើសុំមតិកែលម្អ និងធានាថាសំឡេងរបស់ពួកគេត្រូវបានស្តាប់ និងគោរព។

**កិច្ចសហការ និងភាពជាដៃគូ៖** គម្រោងអភិវឌ្ឍន៍សហគមន៍ជាញឹកញាប់មានការចូលរួមពីភាគីពាក់ព័ន្ធជាច្រើន ដូចជាភ្នាក់ងាររដ្ឋាភិបាលក្នុងតំបន់ អង្គការមិនរកប្រាក់ចំណេញ អាជីវកម្ម និងប្រជាពលរដ្ឋ។ ការកសាងភាពជាដៃគូដ៏រឹងមាំអាចនាំមកនូវជំនាញ ធនធាន និងការគាំទ្រចម្រុះដល់គម្រោង។

**ការកសាងសមត្ថភាព៖** ផ្តល់សិទ្ធិអំណាចដល់សមាជិកសហគមន៍ដោយផ្តល់ការបណ្តុះបណ្តាល និងការគាំទ្រដើម្បីអភិវឌ្ឍជំនាញ ចំណេះដឹង និងសមត្ថភាពភាពជាអ្នកដឹកនាំ។ ការកសាងសមត្ថភាពជួយសហគមន៍ទទួលបានភាពជាម្ចាស់នៃគម្រោង និងធានានូវនិរន្តរភាពរយៈពេលវែងរបស់វា។

**យុទ្ធសាស្ត្រនិរន្តរភាព និងច្រកចេញ៖** ផែនការសម្រាប់និរន្តរភាពរយៈពេលវែងនៃគម្រោងលើសពីដំណាក់កាលអនុវត្តដំបូងរបស់វា។ បង្កើតយុទ្ធសាស្ត្រចាកចេញ ដើម្បីធានាថាអត្ថប្រយោជន៍នៃគម្រោងនៅតែបន្ត បើទោះបីជាការចូលរួមដោយផ្ទាល់បានបញ្ចប់ក៏ដោយ។

**ភាពរសើបនៃវប្បធម៌៖** គោរព និងពិចារណាលើបទដ្ឋានវប្បធម៌ តម្លៃ និងជំនឿរបស់សហគមន៍។ ភាពប្រែប្រួលនៃវប្បធម៌ជំរុញឱ្យមានការជឿទុកចិត្ត និងបង្កើនភាពពាក់ព័ន្ធ និងការទទួលយកគម្រោង។ ការប្រាស្រ័យទាក់ទង និងតម្លាភាព៖ រក្សាទំនាក់ទំនងបើកចំហ និងតម្លាភាពជាមួយអ្នកពាក់ព័ន្ធទាំងអស់។ ធ្វើបច្ចុប្បន្នភាពសហគមន៍ជាទៀងទាត់អំពីវឌ្ឍនភាព បញ្ហាប្រឈម និងដំណើរការធ្វើការសម្រេចចិត្ត។

**ការដាក់បញ្ចូលក្នុងសង្គម៖** ធានាថាគម្រោងនេះគឺរួមបញ្ចូល និងពិចារណាពីតម្រូវការ និងទស្សនៈរបស់សមាជិកសហគមន៍ទាំងអស់ រួមទាំងក្រុមងាយរងគ្រោះ និងក្រុមដែលងាយរងគ្រោះ។ ឧទាហរណ៍ ការបញ្ចូលសមាសភាពស្ត្រីទៅក្នុងការធ្វើផែនការសកម្មភាព និងការសម្រេចចិត្តផ្សេងៗ។

**ការពិចារណាអំពីបរិស្ថាន៖** ដោះស្រាយផលប៉ះពាល់បរិស្ថានដែលអាចកើតមាននៃគម្រោង និងលើកកម្ពស់ការអនុវត្តប្រកបដោយនិរន្តរភាព ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន។

## ៣ អ្នកពាក់ព័ន្ធក្នុងគម្រោង

អ្នកពាក់ព័ន្ធគម្រោងគឺជាអ្នកដែលចាប់អារម្មណ៍លើលទ្ធផលនៃគម្រោងរបស់អ្នក រួមទាំងអ្នកគ្រប់គ្រងគម្រោង ក្រុមការងារនៅក្នុងគម្រោង និងបុគ្គលសំខាន់ៗផ្សេងទៀត។ អ្នកពាក់ព័ន្ធគឺជាមនុស្សដែលនឹងត្រូវបានប៉ះពាល់ដោយគម្រោងរបស់អ្នកនៅគ្រប់ចំណុចនៅក្នុងវដ្តរបស់គម្រោង ហើយការបញ្ចូលពួកគេអាចប៉ះពាល់ដល់លទ្ធផលដោយផ្ទាល់។ វាចាំបាច់ណាស់ក្នុងការអនុវត្តការគ្រប់គ្រងអ្នកពាក់ព័ន្ធឱ្យបានល្អ និងបន្តទំនាក់ទំនងដើម្បីសហការលើគម្រោង។ នៅក្នុងអត្ថបទនេះ យើងនឹងនិយាយអំពីអ្នកពាក់ព័ន្ធធម្មតាសម្រាប់ប្រភេទនៃគម្រោងណាមួយ និងរបៀបកំណត់អត្តសញ្ញាណពួកគេ។

**អ្នកគ្រប់គ្រងគម្រោង (ប្រធាន)៖** គឺជាអ្នកដឹកនាំក្រុម និងទទួលខុសត្រូវលើគម្រោងទាំងមូល។ អ្នកដឹកនាំគម្រោងផ្តល់ការណែនាំ និងការគាំទ្រដល់សមាជិកក្រុមនៅពេលពួកគេបំពេញភារកិច្ចរបស់ពួកគេ។ បន្ថែមពីលើនេះ អ្នកគ្រប់គ្រងគម្រោង នឹងទទួលខុសត្រូវក្នុងការជ្រើសរើសសមាជិកក្រុមការងារ ដែលអាចអនុវត្តការងារ ប្រកបដោយប្រសិទ្ធភាព បើគ្មានការណែនាំពីអ្នកគ្រប់គ្រងគម្រោង ក្រុមការងាររបស់គម្រោងមិនអាចសម្រេចគោលដៅបានទេ។

**សមាជិកក្រុមការងារគម្រោង៖** ក្រុមការងារគម្រោងទទួលខុសត្រូវក្នុងការអនុវត្តគម្រោង និងព្យាយាមបំពេញគ្រប់សកម្មភាពរបស់គម្រោង ដើម្បីសម្រេចលទ្ធផលដែលបានគ្រោងទុក។ ក្រុមការងារគម្រោងគឺជាក្រុមដែល មានជំនាញឯកទេស បច្ចេកទេស សម្របសម្រួល រៀងៗខ្លួន ពួកគេត្រូវសម្របសម្រួលជាមួយសមាជិកក្រុមផ្សេងទៀតនៅពេលអនុវត្តគម្រោង។ ពួកគេមានតួនាទីរាយការណ៍ទៅអ្នកគ្រប់គ្រងគម្រោងក្នុងករណីមានបញ្ហាទាក់ទងនឹងគម្រោង។

**អ្នកទទួលផល៖** គឺជាបុគ្គល ក្រុម សហគមន៍ ឬ អង្គភាព ដែលប្រើប្រាស់លទ្ធផលរបស់គម្រោង និងទទួលបានផលប្រយោជន៍ពីគម្រោង។ អ្នកទទួលផលពីគម្រោងត្រូវបែងចែកជាពីរ (១) អ្នកទទួលប្រយោជន៍ផ្ទាល់ និង (២) អ្នកទទួលប្រយោជន៍ដោយប្រយោលពីគម្រោង។

**ម្ចាស់មូលនិធិ៖** គឺជាបុគ្គល ឬក្រុម ដែលផ្តល់ធនធាន (ថវិកា បច្ចេកទេស សំភារៈ) គាំទ្រដល់គម្រោង។

**ស្ថាប័នជំនាញ និងអជ្ញាធរមូលដ្ឋាន៖** ជាអ្នកជួយគាំទ្រ និងសម្របសម្រួលក្នុងការអនុវត្តគម្រោង។ រាល់គម្រោងសហគមន៍ទាំងអស់ មិនអាចខ្វះការចូលរួមពីអជ្ញាធរមូលដ្ឋាន និងស្ថាប័នជំនាញទេ។

## ៤ ប្រភេទមូលនិធិ

មូលនិធិជាច្រើនត្រូវបានផ្តល់អោយទៅសហគមន៍ ដើម្បីពង្រឹងការអនុវត្តការការពារធនធានធម្មជាតិ និងកែលម្អរជីវភាពរស់នៅក្នុងមូលដ្ឋាន។ មូលនិធិទាំងនេះអាចមានប្រភពមកពីរដ្ឋាភិបាល អង្គការអន្តរជាតិ អង្គការជាតិ ស្ថាប័នឯកជន និងសប្បុរសជនជាដើម។

| ប្រភេទមូលនិធិ | ផុតកំណត់នៃការដាក់ពាក្យ | កាលបរិច្ឆេទនៃការឆ្លើយតប |
|---|---|---|
| មូលនិធិឃុំ (ធនធានធម្មជាតិ អភិវឌ្ឍន៍ ការអប់រំ.....) | ......../........./២០២៣ | ......../........./២០២៣ |
| អង្គការជាតិ/អន្តរជាតិ (ពង្រឹងការអនុវត្តច្បាប់) | ......../........./២០២៣ | ......../........./២០២៣ |
| អង្គការជាតិ/អន្តរជាតិ (ពង្រឹងសមភាពយេនឌ័រក្នុងសហគមន៍) | ......../........./២០២៣ | ......../........./២០២៣ |
| អង្គការជាតិ/អន្តរជាតិ (អនាម័យ និងទឹកស្អាត) | ......../........./២០២៣ | ......../........./២០២៣ |

| | | |
|---|---|---|
| អង្គការជាតិ/អន្តរជាតិ (ស្តារព្រៃលិចទឹកឡើងវិញ) | ......../........./២០២៣ | ......../........./២០២៣ |

## ៥ ដំណើរការនៃការដាក់សំណើគម្រោង

ដំណើរការនៃការដាក់សំណើគម្រោងមានលក្ខណៈខុសៗគ្នាទៅតាមម្ចាស់ជំនួយ ឬ អ្នកឧបត្ថម្ភគាំទ្រ សំណើគម្រោងខ្លះ តម្រូវអោយឆ្លងកាត់ច្រើនជំហាន ប៉ុន្តែការដាក់សំណើគម្រោងខ្លះតម្រូវអោយឆ្លងកាត់ច្រើនជំហានទេ។ តារាងខាងក្រោមនេះបង្ហាញពីដំណើរការទូទៅនៃការរៀបចំសំណើគម្រោង រហូតដល់ការជ្រើសរើស និងចុះកិច្ចព្រមព្រៀងទទួលបានជំនួយៈ

| ជំហាន | កិច្ចការ | សកម្មភាព |
|---|---|---|
| ជំហាន ១ | ប្រកាសអោយដាក់សំណើពីម្ចាស់ជំនួយ រឺ ស្ថាប័នពាក់ព័ន្ធ | ត្រៀមរៀបចំដាក់សំណើ<br>(១) ពិនិត្យពីលក្ខខ័ណ្ឌរបស់ម្ចាស់ជំនួយ តើយើងមានសិទ្ធអាចដាក់បានទេ?<br>(២) ត្រូវកំណត់ពីអាទិភាពការងារ ដែលចង់ស្នើសុំ<br>(៣) ពិនិត្យទម្រង់បែបបទ និងកាលបរិច្ឆេទអោយបានច្បាស់លាស់ មុនដាក់សំណើសុំ |
| ជំហាន ២ | រៀបចំឯកសារសម្រាប់ដាក់សំណើគម្រោង | រៀបចំក្រុមការងារ<br>ឯកសារពាក់ព័ន្ធ<br>អនុវត្តតាមការណែនាំ និងទម្រង់នៃដំណើរការដាក់ពាក្យ |
| ជំហាន ៣ | ដាក់សំណើគម្រោង | ផ្ទៀងផ្ទាត់អោយបានច្បាស់លាស់ មុនដាក់សំណើ<br>ផ្ទៀងផ្ទាត់ពីការជូនដំណឹង និងកាលបរិច្ឆេទក្នុងការសម្រេចរបស់ម្ចាស់ជំនួយ |
| ជំហាន ៤ | ការចម្រាញ់ | នៅក្នុងដំណាក់នេះ គម្រោងរបស់អ្នក អាចត្រូវបានគេពិនិត្យ និងប្រៀបធៀបជាមួយអ្នកផ្សេងទៀត ដើម្បីអាចបន្តទៅជំហានបន្ទាប់ |
| ជំហាន ៥ | ការជ្រើសរើស | ប្រសិនបើគម្រោងរបស់អ្នកល្អ និងត្រូវទៅតាមការចង់បានរបស់ម្ចាស់ជំនួយ គម្រោងរបស់អ្នកនឹងត្រូវបានគេជ្រើស |

| | | |
|---|---|---|
| | | រើស ហើយបន្តទៅជំហានចុះកិច្ចព្រមព្រៀងទទួលជំនួយដើម្បីអនុវត្តគម្រោង |
| ជំហាន ៦ | កិច្ចព្រមព្រៀង | អ្នកទទួលខុសត្រូវលើគម្រោង នឹងត្រូវចុះកិច្ចសន្យាជាមួយម្ចាស់ជំនួយ។ នៅក្នុងកិច្ចព្រមព្រៀង ជំនួយអាចត្រូវផ្តល់អោយជាដំណាក់កាល រឺ ផ្តល់អោយទាំងអស់ អាស្រ័យលើលក្ខខណ្ឌរបស់ម្ចាស់ជំនួយ និងផែនការសកម្មភាពរបស់គម្រោងដែលបានស្នើសុំ។ |

## ៥ ទម្រង់នៃសំណើគម្រោង

ទម្រង់នៃសំណើគម្រោងមានភាពផ្សេងៗគ្នា អាស្រ័យលើការកំណត់របស់ម្ចាស់មូលនិធិ។ ជាទូទៅ នៅកម្រិតសហគមន៍ គេតែងតែបង្កើតភាពងាយស្រួលដល់សហគមន៍ក្នុងការបំពេញគម្រោងស្នើសុំ ដោយភ្ជាប់នៅគំរូស្នើសុំ និងទាមទារអោយសហគមន៍ប្រើប្រាស់ភាសារជាតិជាគោល ក្នុងការសរសេរ។ ទម្រង់ស្នើសុំត្រូវបានកែសម្រួល ដើម្បីអោយមានភាពងាយស្រួលដល់សហគមន៍ ស្វែងយល់ និងអាចសរសេរស្នើដោយខ្លួនឯងបាន។ នៅក្នុងឯកសារបណ្តុះបណ្តាលនេះបានភ្ជាប់នូវទម្រង់មួយចំនួន ដែលសហគមន៍អាចស្វែងយល់និងយកទៅអនុវត្តលើការងារ មានដូចជា៖ (១) គំរូនៃទម្រង់សំណើគម្រោងបែបសាមញ្ញត្រូវបានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី១ (២) គំរូទំរង់ផែនការសកម្មភាពរបស់គម្រោងមានភ្ជាប់នៅឧបសម្ព័ន្ធទី២ (៣) គំរូគម្រោងផែនការ និង តារាងត្រួតពិនិត្យតាមដាន វាយតម្លៃ (៤) គំរូកំណត់ហេតុ និងរបាយការណ៍និងនៅក្នុងឧបសម្ព័ន្ធទី៤ ដល់ទី ៦។ ឯកសារគម្រោងសំណើសង្ខេបគួរតែសរសេរឲ្យខ្លី និងច្បាស់លាស់ ដែលអាចមានពី ៥ ទៅ១០ ទំព័រ។ ឯកសារនេះអាចសរសេរដោយដៃ ឬវាយកំព្យូទ័រក៏បាន។ ឯកសារគម្រោងសំណើសង្ខេបនេះ រួមបញ្ចូលនូវព័ត៌មានដូចខាងក្រោម ៖

**១. ព័ត៌មានទូទៅ៖**

***ឈ្មោះគម្រោង៖*** ..........................................................................................................

(ជាធម្មតាឈ្មោះគម្រោងគួរតែឆ្លុះបញ្ចាំងពីអ្វីដែលគម្រោងរំពឹងថានឹងសម្រេចបាន)

***ទីតាំងគម្រោង៖*** ភូមិ ..............ឃុំ............... ស្រុក........... ខេត្ត................................................

(ចំនួនភូមិ តំបន់គោលដៅរបស់គម្រោង)

***ឈ្មោះសហគមន៍៖*** ....................................................................................................

***អាស័យដ្ឋានរបស់សហគមន៍៖*** .....................................................................................

***អង្គការដៃគូប្រសិនមាន៖*** ..........................................................................................

(សរសេរបញ្ជីឈ្មោះអង្គការ ស្ថាប័នរដ្ឋាភិបាល ក្រុមហ៊ុនឯកជន ដែលបានជួយក្នុងការអនុវត្តគម្រោង)

*ថវិកាគម្រោងសរុប៖*

ចំនួនថវិកាគម្រោងដែលស្នើសុំ៖.......................................................................

ចំនួនថវិកាជាបដិភាគរបស់អង្គការនានា និងសហគមន៍មូលដ្ឋាន៖.....................................

*រយៈពេលអនុវត្តគម្រោង៖* រយៈពេលអនុវត្តអាចមានរយៈពេល .....................................................

**២. ការពិពណ៌នាពីគម្រោង៖**

*ការថ្លែងពីបញ្ហា៖* .............................................................................................................

(សេចក្តីអធិប្បាយសង្ខេបអំពីបញ្ហាកើតមានក្នុងសហគមន៍នេសាទ )

*គោលបំណងជាក់លាក់របស់គម្រោង៖* ........................................................................

(សូមពន្យល់ តើគម្រោងចង់សម្រេចបានអ្វី?)

*លទ្ធផលរំពឹង/វិធីសាស្រ្តដោះស្រាយ៖* ......................................................................

(រៀបរាប់ពីវិធីសាស្រ្តដោះស្រាយ និងលទ្ធផលរំពឹងទុក ដែលកើតពីការអនុវត្តគម្រោង)

*សកម្មភាព៖* ..........................................................................................................

..........................................................................................................

(កំណត់សកម្មភាពជាក់លាក់ទាំងឡាយណា ដែលគម្រោងនឹងអនុវត្ត ដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុក រយៈពេលខ្លី (outputs) លទ្ធផលរយៈពេលមធ្យម (outcomes) និងលទ្ធផលរយៈពេលវែង (impacts) លើបរិស្ថាន និងសហគមន៍)

*វិធីសាស្រ្តអនុវត្ត និងគ្រប់គ្រងគម្រោង៖* .................................................................

..........................................................................................................

..........................................................................................................

(បញ្ជាក់ពីរបៀបនៃការអនុវត្ត និងគ្រប់គ្រងគម្រោង)

*ការវិភាគហានិភ័យ/ភាពប្រថុយប្រថានរបស់គម្រោង៖* ..................................................

..........................................................................................................

..........................................................................................................

(បញ្ហាក់ពីការលំបាក ឬបញ្ហាទាំងឡាយណាដែលអាចកើតមានឡើងក្នុងពេលអនុវត្តគម្រោង និងលើកឡើងនូវសកម្មភាពដែលសហគមន៍អ្នកត្រៀមដោះស្រាយ ដើម្បីទប់ទល់នឹងការលំបាកទាំងនេះ)

*ភាពជាដៃគូ៖*..........................................................................................................

..........................................................................................................

(ពិពណ៌នាពីការភ្ជាប់ទំនាក់ទំនង ឬការសហការជាមួយអ្នកពាក់ព័ន្ធផ្សេងៗក្នុងសហគមន៍)

*ថវិកាសម្រាប់គម្រោង៖*

តម្លៃផ្នែករដ្ឋបាល៖ ..........................................................................................

(រួមបញ្ចូល ប្រាក់ខែបុគ្គលិក ថ្លៃធ្វើដំណើរ ទំនាក់ទំនង ...។ល។ ជា)

តម្លៃផ្នែកកម្មវិធី៖ ..........................................................................................

(ចំណាយលើសកម្មភាព របស់គម្រោងទាំងមូល)

*ចំនួនបដិភាគពីអង្គការ/ម្ចាស់ជំនួយនានា/ស្ថាប័នជាដៃគូ/សហគមន៍៖*...........................................

(ការចូលរួមបដិភាគរបស់សហគមន៍ និង/ឬបានមកពីភ្នាក់ងារផ្តល់ជំនួយនានា ទោះជាក្នុងទម្រង់ជាទឹកប្រាក់ក្តី ឬជារបស់របរក្តីនិងជាសេវាកម្មផ្សេងៗក្តី។)

## ៦. លិខិតរដ្ឋបាល របាយការណ៍ និងកំណត់ហេតុ

ក្រៅពីការបណ្តុះបណ្តាលសមត្ថភាពសហគមន៍នេសាទលើការសរសេរ គម្រោងស្នើសុំ យើងបានពង្រឹងសមត្ថភាពសហគមន៍នេសាទលើការសរសេរបែបបទរដ្ឋបាលមួយចំនួនដូចជា លិខិតស្នើសុំដកថវិកា កំណត់ហេតុ ផែនការសកម្មភាព ផែនការថវិកា និងរបាយការណ៍ទូទាត់។ ទម្រង់លំអិតនៃលិខិតទាំងនេះ គឺមាននៅក្នុងឯកសារគោលការណ៍ណែនាំ **ការប្រើប្រាស់ថវិកាយូរអង្វែងសម្រាប់ការងារគ្រប់គ្រងសហគមន៍នេសាទ** ដែលផ្តោតជាសំខាន់លើការប្រើប្រាស់មូលនិធិរបស់អង្គការ ស៊ី អាយ។ ជាទូទៅ ទម្រង់នៃកំណត់ហេតុដែលប្រើប្រាស់នៅក្នុងគម្រោងស្នើសុំគឺមានលក្ខណៈស្រដៀងគ្នាទៅនឹងទម្រង់កំណត់ហេតុប្រើប្រាស់ក្នុងការគ្រប់គ្រងថវិកាដែរ ដូច្នេះសហគមន៍មានភាពងាយស្រួលក្នុងការស្វែងយល់។ ចំពោះរបាយការណ៍ វាមានលក្ខណៈខុសគ្នា អាស្រ័យលើសកម្មភាព និងគោលបំណងរបស់គម្រោង។ របាយការណ៍របស់គម្រោងមានលក្ខណៈស្មុគស្មាញជាង ហើយត្រូវការ ការពិពណ៌នាលំអិតអាស្រ័យលើគោលបំណង និងសកម្មភាពនីមួយៗនៅក្នុងគម្រោង (ឧបសម្ព័ន្ធទី ៦)។

**ឧបសម្ព័ន្ធ ១** គំរូទម្រង់គម្រោងស្នើសុំ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សហគមន៍នេសាទ**..................

**ឈ្មោះគម្រោង៖** គម្រោងស្តារ អភិរក្សត្រីមេពូជបឹង .................................. និងលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ

**ទីតាំងគម្រោង៖** ចំណុច................ ភូមិ............. ឃុំ............. ស្រុក............. ខេត្ត................

**អ្នកស្នើសុំ៖** សហគមន៍នេសាទ.....................

សហគមន៍នេសាទ.........ត្រូវបានបង្កើតឡើងដោយមហាសន្និបាតកំណើតដំបូង នៅថ្ងៃទី.........ខែ......... ឆ្នាំ២០......... ដោយរដ្ឋបាលជលផល សហការជាមួយខណ្ឌរដ្ឋបាលជលផល...... និងអាជ្ញាធរស្រុក...... ឃុំ......... ភូមិចំនួន......និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍លើកទី២ចុះថ្ងៃទ.....ខែ......ឆ្នាំ ២០......។

សហគមន៍នេសាទ........មានទីតាំងស្ថិតនៅក្នុងភូមិ........និងភូមិ........ឃុំ........ស្រុក........ខេត្ត.......... ដែលមានសមាជិកសរុបចំនួន.........នាក់ ស្រីចំនួន.......នាក់ និងមានគណៈកម្មការចំនួន.......នាក់ ស្រី........។ ក្នុងនោះចំនួនគ្រួសារសរុប.........គ្រួសារ ។

កន្លែងនេសាទសហគមន៍.........មានទំហំ.........ហិកតា ជាកន្លែងដែននេសាទទឹកសាបមាន បឹងបួរ អូរ ព្រៃក ព្រៃលិចទឹក និងជីវចម្រុះ ដើម្បីធ្វើការគ្រប់គ្រង ថែរក្សាការពារ អភិរក្ស និងអភិវឌ្ឍ ដោយមាន

និយាមការដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

មានព្រំប្រទល់៖

-ខាងជើងទល់នឹង .........

-ខាងត្បូងទល់នឹង .........

-ខាងកើតទល់នឹង .........

-ខាងលិចទល់នឹង .........

ប្រជាពលរដ្ឋចំនួន ៦០គ្រួសារក្នុងនោះ នេសាទត្រី ៤០% មានមុខរបរធ្វើស្រែ ៥០% លក់ដូរ ៥% ចិញ្ចឹមសត្វ១០% ចិញ្ចឹមត្រី២០% រាជការ១៥% កម្មការរោងចក្រ១០% និងក្នុងនោះយើងមានក្រុមស្ត្រី សន្សំ ប្រាក់ចំនួន ២ ក្រុមផងដែរ។

**តំណាងដែលមានសិទ្ធ៖** លោក .................ប្រធានគណៈកម្មការ សហគមន៍នេសាទ....................

លោក ...........អនុប្រធានគណៈកម្មការ.......... សហគមន៍នេសាទ..............

**ស្ថាប័នសហប្រតិបត្តិការ៖** រដ្ឋបាលជលផល អាគារលេខ ១៨៦ មហាវិថីព្រះនរោត្តម សង្កាត់

ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

**កាលបរិច្ឆេទគម្រោង៖** ខែ ............. ឆ្នាំ២០១..... ដល់ខែ ............. ឆ្នាំ ២០១......

**ថ្លៃគម្រោងសរុប៖** ៣ ២៤០ ដុល្លារ (បីពាន់ពីររយសែសិបដុល្លាសហរដ្ឋអាមេរិកគត់)

**ចំនួនដែលស្នើសុំពីមូលនិធិឃុំក្បាលក្របី៖** ១ ០០០ ដុល្លារ (មួយពាន់ដុល្លាសហរដ្ឋអាមេរិកគត់)

## **១.សេចក្តីអធិប្បាយសង្ខេបអំពីបញ្ហាកើតមានក្នុងសហគមន៍នេសាទ**

កន្លែងអភិរក្សត្រីមេពូជX...................ស្ថិតនៅក្នុងកន្លែងនេសាទសហគមន៍...........ភូមិ..........ក្នុងឃុំ............. និងឃុំ............. ស្រុក............. ខេត្ត.............. ដោយកន្លងមកទីកន្លែងនេះ បានទទួលរងនូវការបំផ្លិចបំផ្លាញធនធានធម្មជាតិ ការកាប់បំផ្លាញព្រៃលិចទឹកដែលធ្វើឲ្យបាត់បង់ជម្រកត្រីពងកូន និងវារីសត្វគ្រប់ប្រភេទ ខូចខាតបរិស្ថាន ធម្មជាតិស្ទើរទាំងស្រុង ដោយពិនិត្យឃើញថា ភូមិសាស្ត្រទាំងនេះមានលក្ខណៈល្អប្រសើរដល់ការ អភិរក្សធនធានជលផល និងបរិស្ថានធម្មជាតិ ទើបសហគមន៍នេសាទ.................លើកសំណើគម្រោងដល់អង្គការ NGO ដើម្បីស្តារស្ថានភាពតំបន់នេះឲ្យមានលក្ខណៈកាន់តែល្អប្រសើរឡើង។

### **១.១. បញ្ហានៃស្ថានប្រព័ន្ធអេកូឡូស៊ី**

ការបាត់បង់ធនធានជលផល ការបាត់បង់ព្រៃឈើ ព្រៃលិចទឹកដែលធ្វើឲ្យបាត់បង់ទីជម្រកត្រីពងកូន និង វារីសត្វគ្រប់ប្រភេទ ខូចខាតបរិស្ថានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី ជាហេតុនាំឲ្យប៉ះពាល់ដល់ការរស់នៅរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេសាទ ក្នុងការប្រកបមុខរបរចិញ្ចឹមជីវិត ជាពិសេសអ្នកនេសាទ និងអ្នកប្រកបរបរកសិកម្ម លើសពីនេះទៀតក៏ប៉ះពាល់ដល់ក្រុមស្ត្រី ផងដែរ។

### **១.២. បញ្ហានៃផលប៉ះពាល់**

- ផលប៉ះពាល់បណ្តាលមកពីការបំផ្លិចបំផ្លាញធនធានធម្មជាតិ ការកាប់បំផ្លាញព្រៃលិចទឹក និងការប្រែប្រួល អាកាសធាតុ មានឥទ្ធិពលមកលើប្រព័ន្ធអេកូឡូស៊ីជាគោលដៅ និង ផ្អែកតាមការវិភាគផលប៉ះពាល់នៃការប្រែ

ប្រែប្រួល អាកាសធាតុដែលបានធ្វើទៅលើភូមិទាំង ១៦ ក្នុង០២ឃុំ និងតាមការវាយតម្លៃតាមបែបវិទ្យាសាស្រ្ត នូវហានិភ័យ អាកាសធាតុអាចប៉ះពាល់មកលើសហគមន៍ :

- ខ្វះខាតស្បៀងសម្រាប់ហូបចុក
- ខ្វះខាតទឹកសម្រាប់ប្រើប្រាស់ និងធ្វើកសិកម្ម
- កើតមានសត្វល្អិតបំផ្លាញផលដំណាំ
- កើតជំងឺមនុស្ស និងសត្វជាច្រើន
- បាត់បង់ព្រៃឈើ និងព្រៃលិចទឹក
- បាត់បង់ពូជត្រី និងវារីសត្វគ្រប់ប្រភេទ

## ២.គោលបំណងនៃគម្រោង

-ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបដែលបានលុប ឬកាត់បន្ថយពីឡូត៍នេសាទ កន្លែងនេសាទគ្រួសារដែល រក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទកន្លែងនេសាទបំរុងទំនាបលិចទឹកក្នុងរដូវតំឡើងនាទីព្រៃលិចទឹក

-ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជល ផល ជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌

-ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមតយៈការអភិវឌ្ឍន៍ចម្រុះដោយមានការចូលរួម

-ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនិងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ។

-កែលំអ ស្តារដីកន្លែងអភិរក្សត្រីមេពូជ ដាំដើមឈើ និងព្រៃលិចទឹកបន្ថែមទៀត បង្កើនមុខរបរបន្ថែមដោយ មានលក្ខណៈបច្ចេកទេសដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ

-ឲ្យប្រជាពលរដ្ឋខ្មែរបានយល់ដឹងហើយចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ និងចូលរួមការពារ ថែរក្សាប្រភពធនធានធម្មជាតិ លើកកម្ពស់យែនឌ័រ ពិសេសក្រុមស្ត្រី និងសមាជិកសហគមន៍។

ដើម្បីឆ្លើយតបនឹងទស្សនៈវិស័យរបស់សហគមន៍...........................ក្នុងការចូលរួមគ្រប់គ្រង និងប្រើប្រាស់ ធនធាន ជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

## ៣. សេចក្តីអធិប្បាយអំពីវិធីសាស្រ្តដោះស្រាយ

-ឆ្លើយតបទៅនឹងផលប៉ះពាល់បណ្តាលមកពីការបំផ្លិចបំផ្លាញធនធានធម្មជាតិ ការកាប់បំផ្លាញព្រៃលិចទឹក និងការប្រែប្រួលអាកាសធាតុដែលមានឥទ្ធិពលមកលើប្រព័ន្ធអេកូឡូស៊ី ហើយដែលប្រជាពលរដ្ឋ និងសមាជិកសហគមន៍នេសាទភាគច្រើនមិនទាន់មានការយល់ដឹងពីសារៈសំខាន់នៃប្រភពធនធាន ពីការចូលរួមសហគ្រប់គ្រងលើធន ធានធម្មជាតិ និងយុទ្ធសាស្រ្តបន្សាំ ប្រសិនបើមានការប្រែប្រួលអាកាសធាតុកាន់តែធ្ងន់ធ្ងរជាងនេះនោះ បណ្តា

ញ សង្គម គ្រួសារ សាសនា ក្នុងមូលដ្ឋាន ក៏មិនអាចជួយ ពេលមានគ្រោះមហន្តរាយដល់សហគមន៍ទាំងមូលបាន គឺ :

-សហគមន៍នេសាទ ស្ថាប័នជំនាញ អាជ្ញាធរ បានរកយុទ្ធសាស្ត្រមួយចំនួន ដើម្បីស្តារឡើងវិញ និងទប់ស្កាត់នូវសកម្មភាព ទាំងឡាយដែលកើតឡើងដោយសារសកម្មភាពរបស់មនុស្ស និងរបស់ធម្មជាតិ បណ្តាលឲ្យមានផលប៉ះពាល់ ការបាត់បង់ធនធានធម្មជាតិ និងបង្កឲ្យមានគ្រោះមហន្តរាយគ្រោះរាំងស្ងួត ខ្យល់ព្យុះ ទឹកជំនន់ ដោយដាក់ចេញនូវវិធានការកែលំអ ជាច្រើនដូចជា ការអប់រំ ផ្សព្វផ្សាយ ស្តារឡើងវិញ ការពារថែរក្សា អភិរក្ស អភិវឌ្ឍ ជាដើម ដោយមានការចូលរួមពីសមាជិកសហគមន៍នេសាទ ពលរដ្ឋក្នុងមូលដ្ឋាន និងការចូលរួមជួយពីព្រះសង្ឃ ស្ថាប័នជំនាញ អាជ្ញាធរ អង្គការជាតិ អន្តរជាតិ និងកាកបាទក្រហមផងដែរ។

-យុទ្ធសាស្ត្រមួយចំនួនដែលប្រជាពលរដ្ឋបានប្រើប្រាស់ក្នុងការដោះស្រាយហានិភ័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរួមមានការដាំព្រៃលិចទឹក ការស្តារបឹង ព្រែក ប្រឡាយទឹក ជួសជុលទំនប់ អាងទឹក ការប្រើប្រាស់ជានិរន្តរ៍ វិធានការបន្សាំ និងការប្តូរពូជស្រូវធ្ងន់មកធ្វើស្រូវស្រាល មានរយៈពេលខ្លីវិញ។

## ៤. សេចក្តីអធិប្បាយអំពីការលើកស្ទួយគម្រោង (មើលក្នុងផែនការគ្រប់គ្រង)

**គោលបំណងទី ១៖** ការកែលំអ កន្លែងអភិរក្សត្រីមេពូជ X................និង X................

**លទ្ធផល ១.១.** តំបន់អភិរក្សត្រីមេពូជX................ និងX................ ត្រូវបានអភិរក្ស និងកំណត់ព្រំប្រទល់ច្បាស់លាស់ដោយមានការទទួលស្គាល់ពីរដ្ឋបាលជលផល និងអាជ្ញាធរមូលដ្ឋាន

**សកម្មភាព ១.១.១.** ស្តាររណ្តៅអភិរក្សត្រីមេពូជ នៅកន្លែងអភិរក្សត្រី................ដែលមានបណ្តោយ ៤៥ ម៉ែត្រ ទទឹង ៣៥ ម៉ែត្រ និងជំរៅ ០៤ ម៉ែត្រ បន្ថែម(៤៥មX៣៥មX៤ម)។

**សកម្មភាព ១.១.២.** បន្តចាក់គ្រឹះជើងបង្គោលដែលបានដាំរួច និងដាំថ្មីចំនួន ១២០៧ ដើមទៀត ទំហំ (0.១០មX0.១០មX២.៣ម)

**សកម្មភាព ១.១.៣.** ដាក់សម្រាស់ចូលក្នុងរណ្តៅអភិរក្សត្រីមេពូជទាំងបីកន្លែងX........... និង............

**សកម្មភាព ១.១.៤.** ដាក់ស្លាកសញ្ញាហាមឃាត់មន្លែមចំនួន ១០ ស្លាក និងផ្ទាំងប៉ាណូបង្ហាញទិសដៅ ០២ កន្លែង(................និង................)។

**សកម្មភាព ១.១.៥.** សកម្មភាពល្បាតទប់ស្កាត់បទល្មើសនេសាទ និងការពារថែរក្សាព្រៃលិចទឹកដែលមានស្រាប់ និងទើបដាំថ្មីចំនួន ៧៦១៤៥ ម៉ែត្រក្រឡា សម្រាប់ជាជម្រកមច្ឆជាតិ និងវារីសត្វគ្រប់ប្រភេទបន្តពូជទៅថ្ងៃអនាគត និងធ្វើឲ្យបរិស្ថានធម្មជាតិមានភាពស្រស់បំព្រងជានិច្ច រួមចំណែកមួយផ្នែកតូចក្នុងការបន្សាំទៅ និងការប្រែប្រួលអាកាសធាតុនាពេលបច្ចុប្បន្ន។ ប្រជាពលរដ្ឋមានជីវភាពធូរធារតាមរយៈការកើនឡើងនូវផលត្រី និងព្រៃលិចទឹកក្នុងអាងធម្មជាតិ (................និង................)។

**គោលបំណងទី ២៖** បង្កើនព្រៃលិចទឹក និងផលត្រីក្នុងកន្លែងអភិរក្សត្រីមេពូជទាំងបីកន្លែង(................ និង................)

**លទ្ធផល ២.១.** ព្រៃលិចទឹកទំហំ២១៦២៥ ម២ ត្រូវបានដាំបន្ថែម និងដាក់សម្រាស់ក្នុងកន្លែងអភិរក្សលើផ្ទៃដីទំហំ ៧០២៥០ ម២

**សកម្មភាព ២.១.១.** ដាំព្រៃលិចទឹកក្នុងកន្លែងអភិរក្ស................ ................ប្រមាណ ៥៤០៦ ដើម

**សកម្មភាព ២.១.២.** ទិវាលែងកូនត្រីក្នុងកន្លែងអភិរក្សទាំងបី ចំនួន ១០០០០ កូនត្រី

**គោលបំណងទី ៣៖** រៀបចំក្រុមស្រ្តីសន្សំប្រាក់ដើម្បីបង្កើនមុខរបរដល់សមាជិកសហគមន៍នេសាទ

**លទ្ធផល ៣.១.** បង្កើនមុខរបរដល់គ្រួសារដែលបានប្រគល់ឧបករណ៍នេសាទល្មើសច្បាប់ជូនដល់អាជ្ញាធរ និងសហគមន៍នេសាទ

**សកម្មភាព ៣.១.១.** បង្កើតក្រុមស្រ្តីសន្សំប្រាក់ដែលជាគ្រួសារដែលបានប្រគល់ឧបករណ៍នេសាទខុសច្បាប់ និងគ្រួសារក្រីក្រដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន(ជ្រើសរើសសមាជិក និងគណៈកម្មការក្រុមសន្សំ)

**សកម្មភាព ៣.១.២.** បង្កើតលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងរបស់ក្រុមសន្សំប្រាក់ ដោយមានការចូលរួមពីអាជ្ញាធរ មូលដ្ឋាន

**សកម្មភាព ៣.១.៣.** បើកវគ្គបណ្តុះបណ្តាលពីការគ្រប់គ្រង របៀបសន្សំ និងកត់ត្រាបញ្ជីចំណូល ចំណាយ

**គោលបំណងទី ៤៖** អប់រំផ្សព្វផ្សាយអំពីសារៈសំខាន់នៃការគ្រប់គ្រងធនធានធម្មជាតិ

**លទ្ធផល ៤.១.** បំបាត់ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់(ការពារពូជត្រី ព្រៃលិចទឹក)

**សកម្មភាព ៤.១.១.** បើកវគ្គបណ្តុះបណ្តាលស្តីពីសារៈសំខាន់នៃការគ្រប់គ្រងធនធានធម្មជាតិ បឹង............. និងកន្លែងអភិរក្សត្រីមេពូជ.................

**សកម្មភាព ៤.១.២.** ពង្រឹងក្រុមល្បាត ចុះត្រួតពិនិត្យ និងការពារបឹង................ដោយសហការជាមួយសង្កាត់ រដ្ឋបាលជលផល................ កំលាំងមានសមត្ថកិច្ច និងអាជ្ញាធរមូលដ្ឋាន

**សកម្មភាព ៤.១.៣.** ផ្តល់បច្ចេកទេសចិញ្ចឹមត្រីដល់អ្នកដែលមានឧបករណ៍នេសាទខុសច្បាប់ ដែលបានប្រគល់ឧបករណ៍នេសាទល្មើសច្បាប់ជូនដល់អាជ្ញាធរ និងសហគមន៍នេសាទ ដើម្បីកាត់បន្ថយបទល្មើសនេសាទ និងលើកកំពស់ជីវភាពរស់នៅក្នុងគ្រួសារ និងជួយថែរក្សាការពារធនធានមច្ឆាជាតិ

## ៥. ការគ្រប់គ្រងគម្រោង

- <u>រចនាសម្ព័ន្ធគ្រប់គ្រង</u>

-រចនាសម្ព័ន្ធរបស់ សហគមន៍នេសាទ........................... រួមមានៈ

១.លោក ................ ប្រធាន សហគមន៍នេសាទ................និងជានាយកគម្រោង

២.លោក ................ អនុប្រធាន សហគមន៍នេសាទ................ទទួលបន្ទុកការងារគ្រប់គ្រង ហិរញ្ញវត្ថុ របាយការណ៍រីកចំរើនគម្រោង

- <u>ទំនាក់ទំនងនិងការទទួលខុសត្រូវរបស់អ្នកលើកស្នើគម្រោង និងដៃគូរនៅក្នុងគម្រោងនេះ</u>

សហគមន៍នេសាទ................បានទទួលជំនួយឧបត្ថម្ភពីអង្គការ <u>MRC,FMG-IDRC-UNDP</u> ដោយផ្តោតសំខាន់លើៈ

-ការអប់រំផ្សព្វផ្សាយពីសារៈសំខាន់នៃការគ្រប់គ្រងធនធានធម្មជាតិ

-ការកែលំអកន្លែងអភិរក្សត្រីមេពូជ

-សកម្មភាពល្បាត និងទប់ស្កាត់បទល្មើសនេសាទ

-ដាំព្រៃលិចទឹកឡើងវិញ

-រៀបចំក្រុមស្រ្តីសន្សំប្រាក់

ដោយបានជួយបណ្តុះបណ្តាល និងផ្តល់បច្ចេកទេសដល់សហគមន៍ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ របាយការណ៍រីកចំរើន ការតាមដាននិងវាយតម្លៃ សំរាប់ផ្តល់ជូនម្ចាស់ជំនួយឲ្យបានត្រឹមត្រូវ និងសម្រេចបានគោលបំណងនៃគម្រោងនេះឲ្យមាននិរន្តរភាពក្រោយពេលគម្រោងបានបញ្ចប់ ។

## <u>ការគ្រប់គ្រងហានិភ័យ</u>

គណៈកម្មការនិងសមាជិកសហគមន៍នេសាទ..................បានចូលរួមជាមួយស្ថាប័នជំនាញ អាជ្ញាធរ អង្គ ការដៃគូ ក្នុងការវាយតម្លៃហេតុប៉ះពាល់ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ និងចូលរួមវគ្គបណ្តុះបណ្តាល អំពីការប្រែប្រួលអាកាធាតុ ជាពិសេសការកាត់បន្ថយ និងបន្សាំ ដើម្បីកាត់បន្ថយការប៉ះពាល់ហានិភ័យដែលបានកើត ឡើងដាយថាហេតុ និងរកយុទ្ធសាស្រ្តត្រៀមបង្ការនៅពេលមានគ្រោះមហន្តរាយផ្សេងៗកើតឡើងដូចជាភ្លើងឆេះព្រៃ ទឹកជំនន់ ខ្យល់ព្យុះ គ្រោះរាំងស្ងួត ជាដើម។

- <u>**ក្នុងពេលបច្ចុប្បន្ន :**</u>

-ការប្រែប្រួលអាកាសធាតុបានកើតមានឡើងជាបន្តបន្ទាប់ដោយកាលមុនរដូវនីមួយៗមានការទៀងទាត់ទៅ តាមពេលវេលា ដូចជារដូវក្តៅនៅខែមេសា រដូវភ្លៀងធ្លាក់ នៅ<u>ខែ ឧសភា រហូតដល់ខែ កញ្ញា</u> រដូវត្រជាក់នៅ ខែ

តុលា ដល់ខែ ធ្នូ និងកូនរដូវប្រាំមានក្នុងខែ កក្កដា។ តែបច្ចុប្បន្ននេះអាកាសធាតុកើតមានឡើងខុសពីប្រក្រតីក្នុងសហគមន៍ ដោយរដូវភ្លៀងចាប់ផ្តើមតាំងពីខែ មេសា គ្រោះរាំងស្ងួតមានក្នុងខែ សីហា និងខែ កញ្ញា ទឹកជំនន់ក្នុងខែ ធ្នូ ចាប់ពីឆ្នាំ ១៩៩៥ រហូតមកដល់បច្ចុប្បន្ននេះ។

-យោងតាមការវិភាគផលប៉ះពាល់ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុទៅលើប្រជាពលរដ្ឋចំនួន ១៦ ភូមិ ក្នុង ០២ ឃុំ បានឲ្យដឹងថា ព្រឹត្តិការណ៍នៃការប្រែប្រួលអាកាសធាតុនេះ មិនកើតឡើងតាមរដូចកាលទេ ពោលគឺកើតឡើងក្នុងចន្លោះពេលដែលធ្លាប់កើតឡើង។

-ផលប៉ះពាល់នៃបាតុភូតទាំងនេះបណ្តាលឲ្យខូចខាតហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ ស្ពាន បាក់ទំនប់ប្រឡាយ ផ្ទះសម្បែង បាត់បង់ជីវិតមនុស្ស សត្វ ផលដំណាំគ្រប់ប្រភេទ ជាពិសេសដំណាំស្រូវ ប្រជាពលរដ្ឋត្រូវភៀសខ្លួនពីភូមិមួយៗ ទៅភូមិមួយទៀតដើម្បីរកទីទួលសុវត្ថិភាព។

-ឥទ្ធិពលនេះបង្កឲ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរមកលើមុខរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋក្នុងសហគមន៍ ដោយភាគច្រើនពឹងផ្អែកទាំងស្រុងលើមុខរបរនេសាទត្រី កសិកម្ម ដាំបន្លែរួមផ្សំ និងចិញ្ចឹមសត្វ។

- **ទៅពេលអនាគត** :

យោងទៅតាមការវិភាគផលប៉ះពាល់បានបង្ហាញឲ្យឃើញថា ការប្រែប្រួលអាកាសធាតុបានផ្លាស់ប្តូរជារៀងរាល់ឆ្នាំ ចាប់ពីឆ្នាំ ១៩៩០ រហូតមកដល់បច្ចុប្បន្នបានពិនិត្យឃើញថា របបទឹកភ្លៀងប្រចាំរដូវកន្លងមកបានប្រែប្រួលខុសពីធម្មតា ដោយចេះតែថយទៅៗ និងខុសរដូវដែលស្របគ្នានិងការធ្វើនិទស្សន៍អំពីអាកាសធាតុផ្អែកលើវិទ្យាសាស្ត្របានឲ្យដឹងថា កំឡុង ៥០ ឆ្នាំតទៅមុខទៀត អាកាសធាតុនៅប្រទេសកម្ពុជានឹងជួបបញ្ហារដូវមិនទៀងទាត់ អាចផ្លាស់ប្តូរពីរដូវប្រាំងមកជារដូវវស្សាវិញ និងពីរដូវវស្សាទៅរដូវប្រាំងវិញ។

## ៦. ផែនការនិរន្តរភាពគម្រោង

យន្តការនៃការបញ្ចប់គម្រោង និរន្តភាពនៃសកម្មភាពគម្រោង នឹងចូលរួមគ្រប់សកម្មភាពជាមួយសហគមន៍នេសាទមូលដ្ឋាន ទាំងការការពារបរិស្ថានធម្មជាតិ ធនធានជលផល ហិរញ្ញវត្ថុ សកម្មភាពនៃការបន្សាំ និងការលើកកម្ពស់ដល់ក្រុមស្ត្រី ដើម្បីឲ្យគម្រោងអាចបន្តទៅមុខទៀតជានិរន្តរភាព ប្រកបដោយលទ្ធផលល្អប្រសើរ ក្រោយពេលបញ្ចប់គម្រោង។

## ៧. ផែនការតាមដាន និងវាយតម្លៃ

-ការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងការតាមដាននិងវាយតម្លៃ

